April 25, 2019

# នាទីកិច្ចការអន្តរជាតិ៖ អ្នកជំនាញកិច្ចការអន្តរជាតិ ព្រមានថា កម្ពុជាពុំអាចដកខ្លួនរួចចេញពីគម្រោង មហិច្ឆតាប្រចាំសតវត្សរបស់ចិនបានឡើយ



**ដោយ មាន ឫទ្ធិ RFA 2019-04-24**

អ្នកជំនាញកិច្ចការអន្តរជាតិព្រមានថា កម្ពុជាពុំអាចដកខ្លួនរួច ចេញពីគម្រោង «គំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយ» របស់មហាយក្សចិនបានឡើយ ដោយសារតែកម្ពុជាពុំមានជម្រើសជាក់ស្តែងដទៃទៀត ក្រៅតែពីពឹងផ្អែកតែទៅលើចិនតែមួយនោះ។ ការលើកឡើងនេះ ស្របពេលដែលមហាយក្សចិន កំពុងរៀបចំព្រឹត្តិការណ៍ដ៏ធំជាលើកទីពីររបស់ខ្លួននៅចុងខែមេសានេះ ហៅថា វេទិកាស្តីពីគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយ ឬវិថីសូត្រថ្មី ដោយមានការចូលរួមពីសំណាក់បណ្តាមេដឹកនាំពិភពលោកជាង ៤០រូប ក្នុងនោះក៏

មានលោក ហ៊ុន សែន ផង។

បណ្ឌិត ខាល ថៃយ័រ (Carle Thayer) សាស្ត្រាចារ្យកិត្តិយសបណ្ឌិតសភាកងទ័ពការពារជាតិអូស្ត្រាលី នៃសាកលវិទ្យាល័យ New South Wales ប្រាប់អាស៊ីសេរីតាមសារអេឡិចត្រូនិកថា ទំនាក់ទំនងរវាងកម្ពុជា និងចិន ក្រោមគម្រោងគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយ មានផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលកម្ពុជា នៃការអភិវឌ្ឍន៍ជាតិ។ លោកថា ទំនាក់ទំនងទ្វេភាគីនេះ មានទ្រង់ទ្រាយធំ ហើយរួមបញ្ចូលនូវវិស័យសំខាន់ៗចំនួន ៧ ក្នុងនោះរួមមាន៖ វិស័យហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ហិរញ្ញវត្ថុ ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ការកសាងសមត្ថភាព វប្បធម៌ និងទេសចរណ៍ និងការការពារបរិស្ថាន។ លោកបន្តថា ចំណែកនៃការផ្តល់មូលនិធិដ៏ធំសម្បើមនេះ មាននៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ល្បឿនលឿន ស្ពាន កំពង់ផែ ព្រះលានយន្តហោះ និងផ្លូវរថភ្លើងល្បឿន។ ឧទាហរណ៍ ដូចជាកាលពីឆ្នាំ២០១៦ ប្រធានាធិបតីចិន លោក ស៊ី ជីនពីង (Xi Jinping) បានមកធ្វើទស្សនកិច្ចនៅក្រុងភ្នំពេញ ហើយបានសន្យាផ្តល់ប្រាក់កម្ចីចំនួន ២ពាន់លានដុល្លារ ឬ ២ប៊ីលានដុល្លារអាមេរិក ក្រោមគម្រោងគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយនេះ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ប្រព័ន្ធផ្លូវថ្នល់នៅកម្ពុជា។

បណ្ឌិត ខាល ថៃយ័រ ព្រមានថា សម្រាប់ពេលបច្ចុប្បន្ននេះ កម្ពុជាគ្មានមធ្យោបាយដកខ្លួនរួចចេញពីគម្រោងផ្លូវមួយខ្សែក្រវាត់មួយរបស់ចិននេះបានឡើយ ពីព្រោះថា បើហ៊ានធ្វើដូច្នេះមែន នោះក្រុងប៉េកាំងនឹងចាត់ទុកហេតុការណ៍នេះថាជាដំណើរវិវឌ្ឍន៍អវិជ្ជមានមួយ។

អ្នកនាំពាក្យរបបក្រុងភ្នំពេញ លោក ផៃ ស៊ីផាន ចាត់ទុកការព្រមានពីសំណាក់អ្នកជំនាញកិច្ចការអន្តរជាតិនេះថា ជាការវិភាគដែលមាននិន្នាការនយោបាយរួចទៅហើយ។ លោកនិយាយការពារថា កម្ពុជាមិនបានយកបរទេសណាមួយធ្វើជាចៅហ្វាយនាយនោះទេ៖ «យើងត្រូវក្រឡេកមើលនយោបាយការបរទេសរបស់យើង ហើយនឹងរដ្ឋធម្មនុញ្ញរបស់យើង។ គឺយើងប្រកាន់ខ្ជាប់ខ្លួនទៅនឹងគោលការណ៍នយោបាយការបរទេសរបស់យើង គឺចម្រុះពណ៌។ ជាការរកទទួលទានគ្រប់កន្លែងទាំងអស់ ដោយយើងចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ហើយការងារបរទេសរបស់យើង គឺយើងអត់មានជាខ្ញុំនរណាមួយនោះទេ។ យើងស្ថិតនៅជាលក្ខណៈអធិបតេយ្យ និងឯករាជ្យនេះឯង។ យើងមិនយកចិន ឬអាមេរិកាំង ធ្វើជាចៅហ្វាយនាយនោះទេ»។

ផ្ទុយពីការអះអាងនេះ អ្នកជំនាញកិច្ចការអន្តរជាតិមួយរូបទៀត បណ្ឌិត អៀ សុផល សាស្ត្រាចារ្យផ្នែកការទូត និងកិច្ចការពិភពលោក

នៃមហាវិទ្យាល័យ Occidental College នៃរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ប្រាប់អាស៊ីសេរីតាមសារអេឡិចត្រូនិកថា ជាការវាយតម្លៃរបស់លោក កម្ពុជាកំពុងផុងខ្លួនកាន់តែជ្រៅស្រាប់រួចទៅហើយទៅក្នុងគម្រោងផ្លូវមួយខ្សែក្រវាត់មួយរបស់ចិននេះ។ លោកថា បើនិយាយពីស្តង់ដារនៃគម្រោងផ្លូវមួយខ្សែក្រវាត់មួយរបស់ចិននេះ គម្រោងនៅកម្ពុជារបស់ចិនមានទំហំតូច ហើយមានតម្លៃទាប ផ្អែកលើតម្រូវការទឹកប្រាក់។ បណ្ឌិត អៀ សុផល ថា របបក្រុងភ្នំពេញ មិនចង់ដកខ្លួនចេញពីគម្រោងការរបស់ចិននេះទេ តែមានតែផុងខ្លួនចូលកាន់តែជ្រៅទៅក្នុងគម្រោងនេះ ដោយថែមទាំងចង់ឲ្យមានការចាយប្រាក់កាសយ័នរបស់ចិនទូទៅដូចប្រាក់ដុល្លារអាមេរិកទៀតផង។

បណ្ឌិត ខាល ថៃយ័រ ពន្យល់ថា កម្ពុជាពុំមានជម្រើសអ្វីជាក់ស្តែងណាមួយ ក្រៅតែពីពឹងផ្អែកតែទៅលើប្រទេសចិននោះឡើយ។ ចិនគឺជាដៃគូពាណិជ្ជកម្មធំជាងគេ ជាអ្នកវិនិយោគបរទេសសំខាន់ជាងគេ និងជាអ្នកផ្គត់ផ្គង់ជំនួយអភិវឌ្ឍន៍ចម្បងមួយរបស់កម្ពុជា។ លោកថា ទំនាក់ទំនងនេះជាទំនាក់ទំនងកេងចំណេញផលប្រយោជន៍ពីគ្នាទៅវិញទៅមក។ ចិនមានប្រទេសក្នុងតំបន់ ដែលខ្លួនអាចពឹងផ្អែកបាន ដើម្បីឲ្យជួយគាំទ្រដល់អត្ថប្រយោជន៍គោលរបស់ខ្លួនចំណែកឯកម្ពុជាវិញ ក៏ត្រូវការការគាំទ្រវិស័យនយោបាយ ការទូត និងសេដ្ឋកិច្ចពីប្រទេសចិនវិញដែរ។

ការព្រមានរបស់អ្នកជំនាញជាបន្តបន្ទាប់នេះ កើតមានឡើងស្របពេលដែលមហាយក្សចិន កំពុងរៀបចំព្រឹត្តិការណ៍ដ៏សំខាន់នៅចុងខែមេសានេះ ជាវេទិកាលើកទីពីរ ស្តីពីគម្រោងផ្តួចផ្តើមផ្លូវមួយខ្សែក្រវ៉ាត់មួយ ដែលមានមេដឹកនាំមកពីបណ្តាប្រទេសក្នុងពិភពលោកប្រមាណ ៤០ នាក់ចូលរួម។ ក្នុងនោះ លោក ហ៊ុន សែន ក៏ជាមេដឹកនាំម្នាក់ដែលទៅចូលរួមព្រឹត្តិការណ៍នេះដែរ ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ មេសានេះ អមដោយការហែហមរដ្ឋមន្ត្រីគ្រាក់ៗ មួយចំនួនរបស់លោក។ សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសឲ្យដឹងថា ក្នុងអំឡុងពេលចូលរួមវេទិកានេះ លោក ហ៊ុន សែន ក៏គ្រោងនឹងចុះហត្ថលេខាលើឯកសារសំខាន់ៗ មួយចំនួនស្តីពីជំនួយរបស់ចិន ព្រមទាំងគម្រោងកិច្ចសហប្រតិបត្តិការនានាផង ក៏ប៉ុន្តែពុំបានបង្ហើបឲ្យដឹងពីតម្លៃទឹកប្រាក់ ដែលចិនគ្រោងជួយ ឬកម្ពុជាគ្រោងខ្ចីបុលបន្ថែមពីចិននាពេលនេះទេ។

ជុំវិញដំណើរទស្សនកិច្ចទៅចូលរួមព្រឹត្តិការណ៍សំខាន់របស់ចិននេះ បណ្ឌិត ខាល ថៃយ័រ មានប្រសាសន៍ថា កម្ពុជារបស់លោក ហ៊ុន សែន គឺជាអ្នកគាំទ្រដំបូងគេចំពោះគម្រោងគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយនេះ។ លោកថា ការចូលរួមរបស់កម្ពុជាក្នុងវេទិកានេះ នឹងគូសបញ្ជាក់សារឡើងវិញថា ខ្លួនគាំទ្រគំនិតផ្តួចផ្តើមវិថីសូត្រថ្មីដែលជាកេរដំណែលរបស់លោកប្រធានាធិបតី ស៊ី ជីនពីង នេះ ហើយបន្ថែមការគាំទ្រគោលនយោបាយចំពោះចិន ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍នេះឡើង។ លោកថា ជាលទ្ធផល ក្រុង

ប៉េកាំងនឹងបន្តផ្ដល់រង្វាន់ឲ្យកម្ពុជាវិញ ឲ្យពង្រីកការគាំទ្រផ្នែកការទូត និងនយោបាយ បន្តទំនាក់ទំនងវិស័យសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការណ៍វិស័យយោធា។ រីឯបណ្ឌិត អៀ សុផល វិញ មានប្រសាសន៍ថា ដោយធ្វើដំណើរទៅចូលរួមវេទិកានេះ មានន័យថា លោក ហ៊ុន សែន ប្ដេជ្ញាចិត្ត ១០០ភាគរយ ក្នុងការបន្តដើរចូលវិថីផ្លូវមួយខ្សែក្រវាត់មួយ ដែលចិនកំពុងគូសវាសនេះ។ លោកបន្តថា វាក៏មានន័យផងដែរថា នឹងមាននយោបាយការទូតបែបអន្ទាក់បំណុល កំពុងរង់ចាំកម្ពុជានៅខាងមុខបន្តទៀត ដែលលោកព្រមានថា កម្ពុជា ត្រូវតែយល់ឲ្យបានច្បាស់ពីបញ្ហានេះ ដោយយកករណីដែលបានកើតឡើងនៅប្រទេសស្រីលង្កា និងប៉ាគីស្ថានជាគំរូស្រាប់។

បណ្ឌិត ខាល ថៃយ៉័រ ក៏យល់ស្របទៅនឹងអំណះអំណាងរបស់បណ្ឌិត អៀ សុផល ដែរ។ លោកថា ចិនជាអ្នកផ្ដល់ជំនួយអភិវឌ្ឍន៍ភាគច្រើនដល់កម្ពុជា ក្នុងទម្រង់ជាកម្ចី ដែលចាំបាច់ត្រូវតែសងទៅឲ្យចិនវិញ។ លោកពន្យល់ថា បើទោះបីជាចិនផ្ដល់ហិរញ្ញប្បទានភាគច្រើនដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជាក៏ពិតមែន តម្លៃជួសជុល និងថែទាំនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទាំងនេះ គឺជាបន្ទុករបស់ប្រទេសម្ចាស់ផ្ទះ។ ការពឹងផ្អែកទៅលើចិនខ្លាំងពេក ដោយសារតែត្រូវសងលុយទៅចិនវិញផង និងចេញថ្លៃចំណាយលើការថែទាំ និងសេវាជួសជុលផង ហេតុការណ៍នេះ អាចបណ្ដាលឲ្យកម្ពុជាធ្លាក់ផុងចូលក្នុងអន្ទាក់បំណុលវ័ណ្ឌករបស់ចិន។ ពេលនោះ លោកពន្យល់ថា កម្ពុជា នឹងមិនមានលទ្ធភាពចេញលុយសងចិនជាប្រក្រតីបានឡើយ ហើយកម្ពុជានឹងត្រូវក្ស័យធន មិនខុសពីករណីនៅប្រទេសប៉ាគីស្ថាន ដែលបច្ចុប្បន្នកំពុងត្រូវការការជួយស្រោចស្រង់ ពីអាមេរិក និងសហគមន៍អន្តរជាតិ។បណ្ឌិត ខាល ថៃយ៉័រ ពន្យល់បន្តថា ក្រុមហ៊ុនរបស់ចិនជាច្រើន មានជាប់ពាក់ព័ន្ធនឹងការផ្ដល់សេវាសាងសង់ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ហើយនឹងយកហេដ្ឋារចនាសម្ព័ន្ធទាំងនេះទៅធ្វើការគ្រប់គ្រងវិញ។ ជាសម្មតិកម្មចិនអាចនឹងក្លាយជាម្ចាស់នៃកំពង់ផែរ និងថែមទាំងព្រះលានយន្តហោះរបស់កម្ពុជាបាននាពេលអនាគត។

គិតត្រឹមដំណាច់ឆ្នាំ២០១៨ កម្ពុជាជាប់ជំពាក់បំណុលមហាមិត្តចិនជាង ៤ពាន់ ៦រយលានដុល្លារអាមេរិក ស្មើនឹងជាង ៤០ភាគរយ ឬជិតពាក់កណ្ដាលនៃបំណុលដែលកម្ពុជាជំពាក់បរទេសសរុប។ នេះមានន័យថា ពលរដ្ឋខ្មែរម្នាក់ៗ ដែលសូម្បីតែទារកទើបកើតមកភ្លាម កំពុងជាប់ជំពាក់បំណុលចិនក្នុងម្នាក់ៗ ជិត ៣០០ដុល្លារអាមេរិក។

គំនិតផ្ដួចផ្ដើម «ផ្លូវមួយ ខ្សែក្រវាត់មួយ» ឬ ហៅថា «វិថីសូត្រថ្មី» នេះ គឺជាមហិច្ឆតាប្រចាំសតវត្សរបស់ចិនដើម្បីពង្រីកឥទ្ធិពលសេដ្ឋកិច្ច ភូមិសាស្ត្រនយោបាយ និងវប្បធម៌របស់ខ្លួនស្របពេលដែលចិនកំពុងឡើងគ្រងតំណែងជាមហាអំណាចមួយនៅលើពិភពលោក។ ក្រោមការគ្រប់គ្រងរបស់ប្រធានាធិបតី ស៊ី ជីងពីង (Xi Jinping) ចិនបានលាតត្រដាង គំនិតផ្ដួចផ្ដើមនេះជាលើកដំបូងកាលពីឆ្នាំ២០១៣ ក្រោមហេតុផលថា ដើម្បីផ្សារភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដើម្បីសម្រួលការផ្លាស់ប្ដូរពាណិជ្ជកម្ម រវាងប្រទេសក្នុង

ទ្វីបអាស៊ីទៅកាន់ទ្វីបអាហ្វ្រិក និងអឺរ៉ុប និងទៅកាន់តំបន់ផ្សេងពីនេះក្នុងពិភពលោក។ ដើម្បីសម្រេចមហិច្ឆតានេះ ចិនអាចនឹងចំណាយទឹកប្រាក់សរុបរហូតដល់ទៅជិត ១០០ពាន់លានដុល្លារ ឬ ១ទ្រីលានដុល្លារ។

តាមរយៈគំនិតផ្តួចផ្តើមនេះ គម្រោងវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដ៏គួរឲ្យទាក់ទាញជាច្រើន ត្រូវបានលាតត្រដាង និងអនុវត្តនៅកម្ពុជាជាបន្តបន្ទាប់រួមមានការសាងសង់ផ្លូវថ្នល់ល្បឿនលឿនផ្លូវរត់ភ្លើងភ្ជាប់ទៅនឹងប្រទេសក្នុងតំបន់ កំពង់ផែទឹកជ្រៅ កំពង់ផែស្ងួតតំបន់សេដ្ឋកិច្ចពិសេស ព្រះលានយន្តហោះអន្តរជាតិជាដើម ដែលគម្រោងទាំងនេះធ្វើឡើងក្រោមរូបភាពជាជំនួយអភិវឌ្ឍន៍ និងកម្ចីបរទេស។ ចិនក៏បានលាតត្រដាងពីផែនការដែលថានឹងជំរុញឲ្យកម្ពុជាអភិវឌ្ឍន៍ផ្លូវថ្នល់ល្បឿនលឿន ឲ្យបានប្រវែង ២.២៣០គីឡូម៉ែត្រនៅទូទាំងប្រទេសកម្ពុជា គិតត្រឹមឆ្នាំ២០៤០ ក្នុងតម្លៃជាទឹកប្រាក់រហូតដល់ទៅជាង ២៦ពាន់លានដុល្លារ។

មជ្ឈមណ្ឌល ដើម្បីការអភិវឌ្ឍសាកល (Center for Global Development-CGD) ដែលមានមូលដ្ឋាននៅរដ្ឋធានីវ៉ាស៊ីនតុន សហរដ្ឋអាមេរិក កាលពីឆ្នាំ២០១៨ បានដាក់បញ្ចូលប្រទេសកម្ពុជាទៅក្នុងចំណោមក្រុមប្រទេសគោលដៅចំនួន ២៣ប្រទេស ដែលកំពុងប្រឈមនឹង «ហានិភ័យបំណុលគួរឱ្យកត់សម្គាល់» នាពេលបច្ចុប្បន្ននេះ។ បន្ថែមពីលើនេះ ការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌល ដើម្បីសន្តិសុខអាមេរិកាំងថ្មី ឬ Center for a New American Security ដែលធ្វើការវាយតម្លៃលើគម្រោងគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយនេះ ចេញផ្សាយនៅដើមខែមេសានេះ ដែលធ្វើការសិក្សាឧទាហរណ៍នៅប្រទេសចំនួន ១០ ក្រោមគម្រោងរបស់ចិននេះ រកឃើញថា គម្រោងរបស់មហាយក្សចិននេះ ធ្វើឲ្យប្រទេសជាម្ចាស់ផ្ទះ បាត់បង់ភាពជាម្ចាស់ មិនមានភាពច្បាស់លាស់ ជាប់ផុងក្នុងអន្ទាក់បំណុល កើនឡើងអំពើពុករលួយ និងតែងតែត្រូវចិន យកទៅគ្រប់គ្រងធ្វើជាទ្រព្យសកម្មរបស់ខ្លួនវិញ។ របាយការណ៍ផ្តល់អនុសាសន៍ជាជម្រើសជំនួសឲ្យគម្រោងវិថីសូត្ររបស់មហាយក្សចិនវិញថា សហរដ្ឋអាមេរិក ផ្តល់នូវជំនួយអភិវឌ្ឍន៍ដែលមិនធ្វើឲ្យប្រទេសម្ចាស់ផ្ទះជាប់ផុងក្នុងបំណុលនោះទេ ហើយសហរដ្ឋអាមេរិកផ្តោតលើពាណិជ្ជកម្មដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ទាំងសង្ខាងចំពោះភាគីពាក់ព័ន្ធ ដែលអនុញ្ញាតឲ្យមានការវិនិយោគវិស័យធុរកិច្ចផ្នែកឯកជន ដល់ទៅទឹកប្រាក់រាប់ពាន់លានដុល្លារ ហើយផ្តល់អត្ថប្រយោជន៍ដល់ប្រទេសទាំងសង្ខាង គឺទាំងសហរដ្ឋអាមេរិក និងប្រទេសទទួល៕